# លក្ខខណ្ឌការងារសម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិ
# នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
# ដំណាក់កាលទី២

( Mid-Term Review of NP-2 )

## ១. សេចក្តីផ្តើម៖

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) គឺជាគណៈកម្មាធិការអន្តរក្រសួងដែលមានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួល និងគ្រប់គ្រងការរៀបចំ និងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅម្យ៉ាងទៀតថា កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

លេខាធិការដ្ឋាននៃ គ.ជ.អ.ប. គឺជាសេនាធិការជូន គ.ជ.អ.ប. ក្នុងការសម្របសម្រួល គ្រប់គ្រងចាត់ចែងការងារប្រចាំថ្ងៃពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាផែនការរយៈពេលវែងសម្រាប់អនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់អង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

គិតរហូតមកដល់ពេលនេះ គ.ជ.អ.ប. បានដឹកនាំ សម្របសម្រួលក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងការអនុវត្តបញ្ចប់ដោយជោគជ័យនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំដំណាក់កាលទី១ (កជទី១) នៅចុងឆ្នាំ២០២០ និងកំពុងដឹកនាំសម្របសម្រួលការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២(កជទី២) បន្តពីកជទី១ដែលត្រូវអនុវត្តពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០។ ឆ្នាំ២០០៥នោះ គឺជាការអនុវត្តឆ្នាំទី៥នៃកជទី២។

ក្នុងឆ្នាំ២០២៤កន្លងមកនេះ ដោយមានការគាំទ្រពីគម្រោង "ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ" របស់កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) ដែលទទួលបានហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន និងហិរញ្ញប្បទានរបស់ UNDP លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំវាយតម្លៃបញ្ចប់ការអនុវត្តកជទី១នាពេលថ្មីនេះ។ លទ្ធផលនៃការវាយតម្លៃនេះនឹងត្រូវប្រើប្រាស់ជាទិន្នន័យដើមគ្រាសម្រាប់ការវាយតម្លៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (កជទី២)។

ការរៀបចំ និងការអនុវត្តកជទី២រយៈពេល១០ឆ្នាំនេះ (២០២០-២០៣០) មានគោលបំណង "**លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រកបដោយបរិយាប័ន្ន សមធម៌សង្គម និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងការកែលម្អដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែល្អប្រសើរឡើង**"។

ដើម្បីឈានទៅដល់ការសម្រេចបានគោលបំណងនេះ **កជទី២**បានកំណត់គោលដៅជាក់លាក់មួយ គឺ

**"ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនឹងមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារនានាក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សា ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ"។**

ដើម្បីធានាដល់ការសម្រេចបានតាមគោលបំណង និងគោលដៅខាងលើ កជទី២ បានកំណត់សមាសភាគជាយុទ្ធសាស្ត្រចំនួន៥ដែលត្រូវរៀបចំ និងអនុវត្ត ដូចខាងក្រោម៖

***សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖*** ផ្តោតទៅលើការបន្តពង្រឹងយន្តការដឹកនាំ សម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តសកម្មភាពជាអាទិភាពនានានៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

***សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ៖*** ផ្តោតលើការបន្តពិនិត្យ និងការកែសម្រួលមុខងារ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង ធនធាន និងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ ព្រមទាំងដើម្បីធានាដល់ការឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសកម្មភាពសេដ្ឋកិច្ច នគរូបនីយកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និន្នាការបម្លាស់ទីរបស់ប្រជាពលរដ្ឋមកកាន់ទីប្រជុំជន ការកើនឡើងនៃតម្រូវការសេវាសង្គម និងតម្រូវការនៃការកាត់បន្ថយហានិភ័យនានាដែលបង្កឡើងដោយគ្រោះធម្មជាតិ ការប្រែប្រួលអាកាស ធាតុ និងវិបត្តិជាសាកល។

***សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖*** ផ្តោតលើគឺការបន្តជំរុញ និងពង្រឹងការអនុវត្តសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រងការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមាន ព្រមទាំងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។

***សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖*** ផ្តោតលើការបន្តរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របព្រមទាំងអាចវិភាជធនធានថវិកាទាំងនោះប្រកបដោយភាពបត់បែនសម្រាប់ការប្រើប្រាសលើអនុវត្តមុខងារនិងកិច្ចការអាទិភាពនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាបលរដ្ឋដែលបានកំណត់នៅក្នុង

ផែនការអភិវឌ្ឍ កម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

**សមាសភាគទី៤៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន៖** ផ្តោតលើការបន្តធ្វើទំនើបកម្មយន្តការ និងនីតិវិធីនៃការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងជាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់នៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ក្រៅពីសមាសភាគទាំង៥ខាងលើ កជទី២ ក៏ផ្តោតលើកិច្ចការអន្តរវិស័យសំខាន់ចំនួន២ គឺ៖

**ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម៖** ផ្តោតលើការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិក ការរៀបចំផែនការ និងការប្រើប្រាស់ធនធាន ព្រមទាំងការចាត់ចែងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើង និងមិនប្រកាន់ជាតិសាសន៍ សាសនា ភេទ ជនមានពិការភាព ជនជាតិដើមភាគតិច និងឆ្លើយតបដល់ក្រុមជនងាយរងគ្រោះនានាក្នុងសង្គមប្រកបដោយបរិយាប័ន្ន និងសមធម៌។

**ការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងហានិភ័យនៃគ្រោះមហន្តរាយនានា៖** ផ្តោតលើការបង្កពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសិក្សា វាយតម្លៃ រៀបចំផែនការគ្រប់គ្រង ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា សំដៅគាំពារសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន។

**កជទី២**ត្រូវអនុវត្តជា២ដំណាក់កាល គឺផែនការអនុវត្តរយៈពេល៥ឆ្នាំលើកទី១ (ផអ៥ទី១) ដែលត្រូវអនុវត្តពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥ និងផែនការអនុវត្តរយៈពេល៥ឆ្នាំដំណាក់កាលទី២ (ផអ៥ទី២) ដែលត្រូវរៀបចំ និងអនុវត្តពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០។

បច្ចុប្បន្ននេះ គ.ជ.អ.ប. បាន និងកំពុងដឹកនាំ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្ត ផអ៥ទី១ ដែលឆ្នាំ២០២៥នេះ គឺជាឆ្នាំចុងក្រោមនៃការអនុវត្ត ផអ៥ទី១ ឬជាឆ្នាំទី៥នៃការអនុវត្ត កជទី២។

ផអ៥ទី១ បានកំណត់នូវលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាដែលត្រូវរៀបចំ និងអនុវត្តតាមសមាសភាគនីមួយៗ ព្រមទាំងបានកំណត់សូចនាករគន្លឹះសំខាន់ៗដែលត្រូវសម្រេចនៅតាមឆ្នាំនីមួយៗ។ ផអ៥ទី១ ត្រូវអនុវត្តតាមរយៈផែនការសកម្មភាពប្រចាំឆ្នាំនីមួយៗ។ ក្នុងន័យនេះ ផ្អែកលើលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងសូចនាករដែលបានកំណត់ក្នុងផអ៥ទី១ គ.ជ.អ.ប. បាន ដឹកនាំ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនីមួយៗ ដែលហៅថា **ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.** ។

ជារួម ក្នុងផែនការប្រចាំឆ្នាំនីមួយៗរបស់ គ.ជ.អ.ប. ក៏បានកំណត់លទ្ធផលរំពឹងទុកតាមសមាសភាគនីមួយៗ សកម្មភាពអាទិភាព និងស្ថាប័នទទួលខុសត្រូវលើការអនុវត្តសកម្មភាពជាអាទិភាពនីមួយៗ និងសូចនាករដែលត្រូវសម្រេចនៅតាមលទ្ធផលរំពឹងទុកនីមួយៗផងដែរ។

ក្នុងក្របខណ្ឌនៃការគ្រប់គ្រងកជទី២ បានតម្រូវឱ្យមានការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ ឬការវាយតម្លៃបញ្ចប់នៃផអ៥ទី១ ដែលការវាយតម្លៃនេះត្រូវអនុវត្តក្នុងអំឡុងឆ្នាំទី៥នៃផអ៥ទី១ គឺក្នុងឆ្នាំ២០២៥ខាងមុខនេះ។

ពាក់ព័ន្ធនឹងការងារនេះ ដោយមានការគាំទ្រពីគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**" របស់កម្មវិធីអង្គការអភិវឌ្ឍសហប្រជាជាតិ(UNDP) ដែលទទួលបានហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន និងហិរញ្ញប្បទានរបស់ UNDP លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២នៅដើមឆ្នាំ២០២៥។ ការវាយតម្លៃនេះត្រូវអនុវត្តដោយទីប្រឹក្សាឯករាជ្យ (individual consultant) ដែលត្រូវជ្រើសរើស និងចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. តាមគោលការណ៍ និងនីតិវិធីជាធរមាន។

## ២. គោលបំណង

ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ ឬការវាយតម្លៃចុងបញ្ចប់នៃផអ៥ទី១នេះ មានគោលបំណងពិនិត្យវាយតម្លៃលើវឌ្ឍនភាពដែលផ្តោតលើរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រៀបធៀបទៅនឹងលទ្ធផលរំពឹងទុកដែលបានកំណត់តាមសមាសភាពនីមួយៗនៃផអ៥ទី១ ព្រមទាំងកំណត់បញ្ហាប្រឈមជាគន្លឹះ និងហានិភ័យនានា ដោយលើកអនុសាសន៍សម្រាប់ដោះស្រាយបញ្ហាប្រឈម និងការកាត់បន្ថយហានិភ័យទាំងនោះផងដែរ ។

លទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២នេះ ក៏ត្រូវប្រើប្រាស់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំតាក់តែងផអ៥ទី២ផង និងជាទិន្នន័យដើមគ្រាសម្រាប់ការវាយតម្លៃបញ្ចប់នៃកជទី២ផងដែរ។

## ៣. ទំហំការងារ Scope of work

ផ្អែកលើគោលបំណងខាងលើ ទីប្រឹក្សាត្រូវបានជ្រើសរើស និងចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវអនុវត្តការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២នេះ ដោយគ្រប់ដណ្តប់លើរាជធានីខេត្តចំនួន៦ រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១២ រដ្ឋបាលឃុំ សង្កាត់ចំនួន២៤ និងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិមួយចំនួន ដែលមានអ្នកចូលរួមសរុបយ៉ាងតិចចំនួន១៥០០នាក់។

ក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២នេះ ទីប្រឹក្សាដែលចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបំពេញកិច្ចការសំខាន់ៗរួមមានដូចជា ការកំណត់វិធីសាស្ត្រ ការរៀបចំបញ្ជីសំណួរ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ ការរៀបចំសេចក្តីព្រាងរបាយការណ៍បឋមស្តីពីរបកគំហើញ ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងការរៀបចំរបាយកាណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃពាក់កណ្តាលអាណត្តិ ដោយរួមបញ្ចូលទាំងអនុសាសន៍នានាសម្រាប់ការរៀបចំតាក់តែង ផអ៥ទី២ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តផអ៥ទី២ផងដែរ។

ទន្ទឹមគ្នានេះ វាយតម្លៃពាក់កណ្ដាលអាណត្តិនៃកជទី២នេះត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីវឌ្ឍនភាព ឬលទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមជាគន្លឹះនានានៃការអនុវត្តតាមសមាសភាគនីមួយៗដែលបានកំណត់ក្នុងផអ៥ទី១ រួមមាន (១) ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ (២) ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣) ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស (៤) វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាបេស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៥) ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ទីប្រឹក្សាវាយតម្លៃពាក់កណ្ដាលអាណត្តិនៃកជទី២ត្រូវបំពេញកិច្ចការទាំងនេះ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋាន គ.ជ.អ.ប. ព្រមទាំងត្រូវមានការពិភាក្សាពិគ្រោះយោបល់ជាមួយក្រុមការងារពិគ្រោះយោបល់នៃគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**"

## ៤. វិធីសាស្ត្រ

វិធីសាស្ត្រដែលត្រូវប្រើប្រាស់ក្នុងការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃ**កជទី២**នេះ រួមមាន៖

- ការសិក្សាលើឯកសារគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត របាយការណ៍ និងឯកសារនានាដែលពាក់ព័ន្ធនឹងការអនុវត្ត **ផអ៥ទី១** (desk review)
- ការប្រមូលព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្ត **ផអ៥ទី១** រួមទាំង ការប្រមូលទិន្នន័យដែលមានស្រាប់នៅក្នុងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនានា (secondary data) និងការប្រមូលព័ត៌មាន និងទិន្នន័យតាមរយៈការជួបពិភាក្សា សម្ភាសន៍ជាមួយក្រុមអ្នកផ្ដល់ព័ត៌មានពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (primary data)។
- ការរៀបចំបញ្ជីសំណួរត្រូវផ្តោតទៅលើការប្រមូលព័ត៌មានដែលពាក់ព័ន្ធទៅនឹងវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តសមាសភាគនីមួយៗនៃផអ៥ទី១។ បញ្ជីសំណួរត្រូវរៀបចំផ្សេងៗគ្នាសម្រាប់ក្រុមផ្តល់ព័ត៌មាននីមួយៗ។
- ការបញ្ចូលទិន្នន័យ និងការវិភាគទិន្នន័យដែលប្រមូលបាន ទាំងការវិភាគបែបវិទ្យាសាស្ត្រ (statistical analysis) និងការវិភាគតាមបែបទស្សនយល់ឃើញ (prescriptive/qualitative analysis) ដោយត្រូវឈរលើគោលការណ៍មិនលំអៀង និងផ្អែកលើលក្ខណៈវិនិច្ឆ័យ ព្រមទាំងមានភស្តុតាងច្បាស់លាស់។
- ការពិភាក្សា និងការពិគ្រោះយោបល់នានាលើរបកគំហើញ និងលទ្ធផលនៃការវិភាគ តាមរយៈការរៀបចំកិច្ចប្រជុំ ឬសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានអ្នកពាក់ព័ន្ធចូលរួមមិនតិចជាង៥០នាក់។

## ៥. ការកំណត់សំណាក

ការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃកជទី២ត្រូវគ្រប់ដណ្តប់លើរាជធានី ខេត្តចំនួន៦ រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១២ រដ្ឋបាលឃុំ សង្កាត់ចំនួន២៤ និងក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិមួយចំនួនដែលមានអ្នកចូលរួមសរុបយ៉ាងតិចចំនួន១៥០០នាក់ ក្នុងនោះអ្នកចូលរួមផ្តល់ព័ត៌មានជាស្ត្រីយ៉ាងតិច

ចំនួន៥០%។ ក្រុមអ្នកផ្តល់ព័ត៌មានដែលត្រូវជួបពិភាក្សា និងសម្ភាសន៍អាចរួមមាន៖

**ក្រុមអ្នកផ្តល់ព័ត៌មាននៅថ្នាក់ជាតិ៖**

- ✓ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.អ.ប.យ៉ាងតិចចំនួន៧ក្រសួង (ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល...)
- ✓ តំណាងដៃគូអភិវឌ្ឍន៍ចំនួន៥ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធចំនួន៥។

**ក្រុមអ្នកផ្តល់ព័ត៌មាននៅថ្នាក់ក្រោមជាតិ៖**

- ✓ រដ្ឋបាលរាជធានី ខេត្តចំនួន៦ដែលត្រូវជ្រើសរើសសម្រាប់ការវាយតម្លៃ ដោយផ្តោតលើភាពតំណាងឱ្យតំបន់ទីប្រជុំជន តំបន់ជនបទ តំបន់ដែលមានលក្ខណចម្រុះ និងតំបន់ដែលមានលក្ខណៈពិសេសដោយឡែក។ សមាសភាពក្រុមអ្នកផ្តល់ព័ត៌មាននៅថ្នាក់រាជធានី ខេត្តទាំងនេះអាចរួមមាន៖ ក្រុមប្រឹក្សា គណៈអភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារនៅអង្គភាពនានានៃរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មការធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- ✓ រដ្ឋបាលក្រុង ស្រុក ខណ្ឌសរុបចំនួន១២ ដោយត្រូវជ្រើសរើសយករដ្ឋបាលក្រុងចំនួន១ និងស្រុកចំនួន១នៅក្នុងរាជធានី ខេត្តគោលដៅនីមួយៗ។ សមាសភាពក្រុមអ្នកផ្តល់ព័ត៌មាន អាចរួមមាន៖ ក្រុមប្រឹក្សា គណៈអភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារនៅតាមអង្គភាពពាក់ព័ន្ធមួយចំនួន និងគណៈកម្មការធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- ✓ រដ្ឋបាលឃុំ សង្កាត់សរុបចំនួន២៤ឃុំ សង្កាត់ ដោយត្រូវជ្រើសរើសយករដ្ឋបាលឃុំ សង្កាត់ចំនួន២ក្នុងក្រុង និងស្រុកគោលដៅនីមួយៗ។ សមាសភាពអ្នកផ្តល់ព័ត៌មាន អាចរួមមាន៖ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន គណៈកម្មាធិការទទួលបន្ទុកការងារស្ត្រី និងកុមារឃុំ សង្កាត់ ក្រុមការងារកសាងផែនការ និងថវិកាឃុំ សង្កាត់ និងក្រុមតំណាងសហគមន៍មូលដ្ឋាននានា។

## ៦. កិច្ចការសំខាន់ៗដែលត្រូវរៀបចំ និងអនុវត្ត

កិច្ចការនានាដែលទីប្រឹក្សាវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ចាំបាច់ត្រូវអនុវត្តក្នុងដំណើរការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២រួមមាន៖

- ការរៀបចំរបាយការណ៍ស្តីពីការចាប់ផ្តើមការវាយតម្លៃពាក់កណ្តាលអាណត្តិ(inception report) ដែលកំណត់អំពីគោលបំណង ដំណើរការ វិធីសាស្ត្រ ឧបករណ៍ ផែនការសកម្មភាព និងក្របខណ្ឌពេលវេលានៃការវាយតម្លៃ និងទម្រង់របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃ
- ការរៀបចំបញ្ជីសំណួរ ដោយមានការពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រុមការងារពិគ្រោះយោបល់នៃគម្រោង"ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ"
- ការប្រមូលព័ត៌មាន និងទិន្នន័យនានា តាមរយៈការសិក្សាស្រាវជ្រាវលើការរបាយការណ៍ និងឯកសារពាក់ព័ន្ធនានា និងការចុះជួបប្រជុំពិភាក្សា និងសម្ភាសន៍ជាមួយក្រុមផ្តល់ព័ត៌មាន

ដែលបានកំណត់ទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- ការបញ្ចូល និងការវិភាគទិន្នន័យដែលប្រមូលបាន
- ការរៀបចំសេចក្តីព្រាងរបាយការណ៍បឋមស្តីពីនៃការរកឃើញសំខាន់ៗ
- ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីរបកគំហើញសំខាន់ៗ ដែលមានអ្នកចូលរួមពីក្រសួង ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាដែលមានចំនួនសរុបមិនតិចជាង៥០នាក់
- ការរៀបចំបញ្ចប់របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ**កជទី២** ដោយផ្អែកលើមតិយោបល់ និងធាតុចូលនានាពីសិក្ខាសាលាពិគ្រោះយោបល់។ របាយការណ៍ចុងក្រោយស្តីពីលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ**កជទី២** ត្រូវរួមបញ្ចូលទាំងសេចក្តីសង្ខេបដែលរៀបរាប់សង្ខេបអំពីវិធីសាស្ត្រ របកគំហើញ និងអនុសាសន៍សម្រាប់ការរៀបចំផអ៥ទី២។ របាយការណ៍នេះត្រូវរៀបចំជាភាសាខ្មែរ និងភាសាអង់គ្លេសតាមទម្រង់ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ។

ទីប្រឹក្សាវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ត្រូវអនុវត្តកិច្ចការចាំបាច់ទាំងនេះ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋាន គ.ជ.អ.ប. និងការពិគ្រោះយោបល់ជាមួយក្រុមការងារពិគ្រោះយោបល់នៃគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**" ព្រមទាំងត្រូវមានការឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប។

## ៧. លទ្ធផលសំខាន់ៗដែលត្រូវសម្រេចបាន (Deliverable)

ទីប្រឹក្សាវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ត្រូវជានាសម្រេចឱ្យបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

| ល.រ | លទ្ធផល | ពេលវេលា | ផ្សេងៗ |
|---|---|---|---|
| ១ | របាយការណ៍ស្តីពីការចាប់ផ្តើមការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ (inception report) | រយៈពេល២សប្តាហ៍ បន្ទាប់ពីចុះកិច្ចសន្យា (ខែមីនា ២០២៥) | ជាភាសាខ្មែរ និងអង់គ្លេស និងត្រូវពិនិត្យ ពិគ្រោះយោបល់ ដោយUNDP ក្រុមការងារពិគ្រោះយោបល់នៃគម្រោង STA និងការឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប |
| | របាយការណ៍ស្តីពីវឌ្ឍនភាពនៃដំណើរការវាយតម្លៃ (ការរៀបចំបញ្ជីសំណួរ និងការចុះប្រមូលទិន្នន័យ) | រយៈពេល៥សប្តាហ៍ បន្ទាប់ពីការឯកភាពលើ inception report (ខែមីនា-មេសា ឆ្នាំ ២០២៥) | |
| ៣ | សេចក្តីព្រាងបឋមនៃរបាយការណ៍ស្តីពីរបកគំហើញនៃការតម្លៃ | រយៈពេល ២ សប្តាហ៍ បន្ទាប់ពីការចុះប្រមូលទិន្នន័យ (ខែឧសភា) | |

| | | | |
|---|---|---|---|
| ៤ | សិក្ខាសាលាពិគ្រោះយោបល់ទៅលើរបកគំហើញនានា | រយៈពេល២សប្តាហ៍ បន្ទាប់ពីការបញ្ចប់សេចក្តីព្រាងរបាយការណ៍ស្តីពីរបកគំហើញ (ខែឧសភា) | |
| ៥ | របាយការណ៍ចុងក្រោយស្តីពីលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ | រយៈពេល២សប្តាហ៍ បន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ (ខែមិថុនា) | |

## ៨. ការជ្រើសរើសទីប្រឹក្សា (Individual consultant)

ទីប្រឹក្សាដែលនឹងត្រូវជ្រើសរើស និងចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការផ្តល់សេវាវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២នេះត្រូវមានលក្ខណៈសម្បត្តិស័ក្តិសម និងបទពិសោធន៍ការងារដូចខាងក្រោម៖

- មានជំនាញវិជ្ជាជីវៈផ្នែកផែនការ ត្រួតពិនិត្យ និងវាយតម្លៃ (Planning and M&E Specialist) ឬមានជំនាញវិជ្ជាជីវៈផ្នែកច្បាប់ និងអភិបាលកិច្ច (Legal & Governance Expert)។
- មានបរិញ្ញាបត្រជាន់ខ្ពស់ (Master Degree) ផ្នែកច្បាប់ ឬផ្នែកគោលនយោបាយសាធារណៈ ឬផ្នែកគ្រប់គ្រងរដ្ឋបាលសាធារណៈ ឬផ្នែកសេដ្ឋកិច្ច ឬផ្នែកទំនាក់ទំនងអន្តរជាតិ ឬផ្នែកគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស
- មានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការត្រួតពិនិត្យ វាយតម្លៃ ការរៀបចំគោលនយោបាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងស្ថាប័ន ការគ្រប់គ្រងកម្មវិធី និងគម្រោងនានាពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចមូលដ្ឋានយ៉ាងហោចរយៈពេល១០ឆ្នាំ។

## ៩. ក្របខណ្ឌពេលវេលា

ទីប្រឹក្សាដែលត្រូវបានជ្រើសរើស និងចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវអនុវត្តការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ឱ្យបានចប់សព្វគ្រប់យ៉ាងយូរក្នុងរយៈពេល **៣,៥ខែ**បន្ទាប់ពីថ្ងៃចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប.។ របាយការណ៍ចុងក្រោយស្តីពីលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិត្រូវដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងខែមិថុនា ឆ្នាំ២០២៥។